**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្ដីប្រកាសព័ត៌មាន**

ថ្ងៃទី ១៨ ខែ មិនា ឆ្នាំ២០១៥

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ២៦៦,៨០០ ដុល្លារអាមេរិក សម្រាប់ វិស័យកសិកម្ម និងវិស័យអប់រំ ក្នុងខេត្តស្វាយរៀង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបចំនួន ២៦៦,៨០០ ដុល្លារអាមេរិក ដល់មន្ទីរកសិកម្មខេត្តស្វាយរៀង សាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបីសម្រាប់គម្រោងដូចតទៅ៖



១. <u>គម្រោងសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មត្នោត ខេត្តស្វាយរៀង (ថវិកាចំនួន១០២,២៤៥ដុល្លារអាមេរិក)</u>

<u>អង្គភាពទទួលជំនួយ៖ មន្ទីរកសិកម្ម ខេត្តស្វាយរៀង</u>

គម្រោងនេះ គឺដើម្បីសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មមួយដែលមានរោង និងម៉ាស៊ីនកិនស្រូវចំនួនមួយគ្រឿង មានឃ្លាំងសម្រាប់ដាក់អង្ករ រោងយាម រោងសម្រាប់ដាក់អង្កាម និងកន្លែងសម្រាប់ផលិតជីធម្មជាតិ។ គម្រោងនេះ ត្រូវបានរំពឹងថា ប្រជាពលរដ្ឋប្រមាណ៥,៥០០នាក់ នឹងទទួលបាននូវជីវភាពរស់នៅកាន់តែប្រសើរឡើង តាមរយៈការលក់អង្ករទៅអោយសហគមន៍កសិកម្មក្នុងតម្លៃមួយសមរម្យ។

២. <u>គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នង នៅក្នុងសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង(ថវិកាចំនួន ៨៧,៩៤៩ ដុល្លារអាមេរិក)</u>



<u>អង្គភាពទទួលជំនួយ៖ សាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង</u>

គម្រោងនេះ គឺដើម្បីសាងសង់មន្ទីរពិសោធន៍វិទ្យាសាស្ត្រមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសាលារៀន និងបង្គន់អនាម័យ នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង។ គម្រោងនេះ ត្រូវបានរំពឹងថា គរុសិស្សប្រមាណ ១២០ នឹងទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ ដែលនឹងក្លាយជាគ្រូបង្រៀនបឋមសិក្សានៅក្នុងបរិស្ថានអប់រំមួយដែលល្អប្រសើរ។



៣. គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាព្រៃម្នាស់ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង(ថវិកាចំនួន ៧៦,៦០៦ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយៈ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាមួយខ្នង ជាមួយនឹងបង្គន់អនាម័យ នៅបឋមសិក្សាព្រៃម្នាស់ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ គម្រោងនេះ សិស្សានុសិស្សប្រមាណជា ៤៥០នាក់ នឹងទទួលបានការសិក្សាក្នុងថ្នាក់រៀនប្រកបដោយសុវត្ថិភាព និងជាសុខភាព។

*ជំនួយឥតសំណង គូសាណូណេ របស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥២.៨លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណេចំនួន៥២៧ គម្រោងនៅទូទាំងប្រទេស។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទៈ ០២៣-២១៧-១៦១ ទូរសារៈ ០២៣-២១៤-៣៣០*
*អ៊ីមែលៈ eco.jpn@pp.mofa.go.jp*
*គេហទំព័រៈ http://www.kh.emb-japan.go.jp*